# អង្គការតម្លាភាពកម្ពុជា

## ការប្រកួតប្រជែងស្នាដៃផលិតវីដេអូ
## «គណនេយ្យភាពសារពើពន្ធសម្រាប់ការកាត់បន្ថយវិសមភាព»

- អ្នកចូលរួមប្រកួតប្រជែងត្រូវជ្រើសរើសយកតែមួយក្នុងចំណោមប្រធានបទដែលបានស្នើខាងក្រោម
- អ្នកចូលរួមក៏ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសប្រធានបទខាងក្រៅផ្សេងទៀត ដរាបណាប្រធានបទមួយនោះស្ថិតនៅក្រោមវិសាលភាពនៃប្រធានបទគោលនៃការប្រកួតទាំងមូល

### I. ប្រធានបទ៖

1. បញ្ឈប់ការគេចវេសពន្ធ!
2. សារប្រយោជន៍នៃការបង់ពន្ធក្នុងការអភិវឌ្ឍជាតិ។
3. ការប្រមូលពន្ធ ដើម្បីលើកកម្ពស់គុណភាពវិស័យអប់រំ។
4. ការប្រមូលពន្ធ ដើម្បីលើកកម្ពស់គុណភាពវិស័យសុខាភិបាល។
5. ការប្រមូលពន្ធ ដើម្បីលើកកម្ពស់គុណភាពការផ្តល់សេវាសាធារណៈ។

### II. ជ័យលាភី៖

អង្គការតម្លាភាពកម្ពុជា នឹងធ្វើការជ្រើសរើសជ័យលាភីវីដេអូឆ្នើមចំនួន ៥រូប៖

- ជ័យលាភីលេខ១ នឹងទទួលបានថវិកាចំនួន $៨០០
- ជ័យលាភីលេខ២ នឹងទទួលបានថវិកាចំនួន $៧០០
- ជ័យលាភីលេខ៣ នឹងទទួលបានថវិកាចំនួន $៦០០
- ជ័យលាភីកេត្តិយសចំនួន ២ នឹងទទួលបានថវិកាចំនួន $២០០

## III. លក្ខខណ្ឌក្នុងការចូលរួមប្រកួត៖

- ជាពលរដ្ឋកម្ពុជាដែលមានអាយុចន្លោះពី ១៥ ទៅ ៣០ ឆ្នាំ
- មានទីលំនៅបច្ចុប្បន្នក្នុងប្រទេសកម្ពុជា
- វីដេអូអាចជាការងារក្រុម ឬការងារបុគ្គល
- ផលិតករវីដេអូត្រូវតែមិនធ្លាប់ទទួលបានជ័យលាភីក្រោមកម្មវិធីការប្រកួតវីដេអូដែលធ្លាប់ត្រូវបានរៀបចំដោយអង្គការតម្លាភាពកម្ពុជាកាលពីមុនៗ
- ផលិតករវីដេអូត្រូវតែមិនមែនជាអ្នកផលិតវីដេអូជំនាញ

## IV. លក្ខខណ្ឌក្នុងការដាក់ពាក្យ៖

- វីដេអូត្រូវតែឆ្លើយតប និងពន្យល់អំពីប្រធានបទដែលត្រូវបានជ្រើសរើស
- វីដេអូត្រូវតែជាស្នាដៃដើមរបស់ផលិតករផ្ទាល់ ដោយគ្មានការថតចម្លងពីអ្នកដទៃ និងពីប្រភពណាទាំងអស់
- វីដេអូត្រូវតែជាភាសារខ្មែរ ដែលមានអក្សររត់ពីក្រោមជាភាសាអង់គ្លេស
- វីដេអូអាចមានទម្រង់ជាប្រភេទគំនូរជីវចល ឬ ខ្សែភាពយន្តខ្លីដែលមានការចូលរួមសម្តែងដោយមនុស្សផ្ទាល់
- ផលិតករវីដេអូជាអ្នកទទួលខុសត្រូវចំពោះការស្រាវជ្រាវរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស

## V. របៀបនៃការដាក់ពាក្យ៖

- ផលិតករ ត្រូវបញ្ចូលវីដេអូទៅក្នុង Dropbox, Google Drive ឬ One Drive រួចហើយផ្ញើតំណភ្ជាប់ (link) មកកាន់អ៊ីម៉ែល lymengchi@ticambodia.org
- ការផ្ញើតំណភ្ជាប់ត្រូវប្រាប់នូវព័ត៌មានផ្ទាល់ខ្លួនរបស់ផលិតករក្នុងសំណើរនៅលើអ៊ីម៉ែលដែលមានដូចជា៖ **ចំណងជើងនៃវីដេអូ ឈ្មោះក្រុមផលិតករ** (បើជាស្នាដៃក្រុម និងមានការបញ្ជាក់ឈ្មោះអ្នកតំណាងក្រុម) **ភេទ ថ្ងៃ/ខែ/ឆ្នាំកំណើត អាស័យដ្ឋានបច្ចុប្បន្ន សាកលវិទ្យាល័យ លេខទូរស័ព្ទទំនាក់ទំនង អ៊ីម៉ែល** និង**កិច្ចព្រមព្រាង** តាមទម្រង់ដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម៖
    - ចំណងជើងវីដេអូ៖ ………………………………..

- ឈ្មោះក្រុម៖ **កូនខ្មែរ**
- ឈ្មោះផលិតករតំណាងក្រុម៖ **ជី លីម៉េង**
- ភេទ៖ **ប្រុស**
- ថ្ងៃ/ខែ/ឆ្នាំកំណើត៖ **២៦ ឧសភា ២០២០**
- អាស័យដ្ឋានបច្ចុប្បន្ន៖ **ភ្នំពេញ**
- សាកលវិទ្យាល័យ៖ **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
- លេខទូរស័ព្ទទំនាក់ទំនង៖ **០៧០ ៧៩៩ ៩៤២**
- អ៊ីម៉ែល៖ lymengchi996@gmail.com
- កិច្ចព្រមព្រាង៖ ដោយចូលរួមក្នុងការប្រកួតប្រជែងនេះ ខ្ញុំបាទ/នាងខ្ញុំ ព្រមទទួលយកល័ក្ខខ័ណ្ឌដែលមានចែងក្នុងទំរង់ពាក្យស្នើសុំ និងយល់ព្រមអនុឡោមតាមការសម្រេចចិត្តចុងក្រោយរបស់គណៈកម្មាធិការវាយតម្លៃ និងដាក់ពិន្ទុ ដោយមិនមាននូវការជំទាស់តវាផ្សេងៗ

## VI. កំណត់សម្គាល់

- ផលិតករ អាចផ្ញើតំណភ្ជាប់បានតែមួយដងប៉ុណ្ណោះ (ការផ្ញើវីដេអូទ្វេដងនឹងមិនត្រូវបានពិចារណាសម្រាប់វីដេអូដែលបានផ្ញើជាលើកទី២)
- ផលិតករវីដេអូត្រូវទទួលខុសត្រូវចំពោះសម្ភារៈផ្ទាល់ខ្លួនដែលត្រូវការសម្រាប់ការផលិតវីដេអូ
- ផលិតករ ត្រូវគោរពអំពីច្បាប់នៃកម្មសិទ្ធបញ្ញា មុននឹងថតយកសកម្មភាព ឬទាញយកកម្រងរូបភាពពីប្រភពណាមួយ
- ផលិតករ ត្រូវទទួលខុសត្រូវក្នុងផ្លូវច្បាប់លើវីដេអូដែលមានជាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- អង្គការតម្លាភាពកម្ពុជា រក្សាសិទ្ធិក្នុងការប្រើប្រាស់វីដេអូ ដែលទទួលបានជ័យលាភី ឬ មិនទទួលបានជ័យលាភីក្នុងកម្មវិធីប្រកួតសម្រាប់ការប្រើប្រាស់ និងផ្សព្វផ្សាយបន្ត
- ផលិតករដែលបំពេញគ្រប់លក្ខណ្ឌខាងលើ និងវីដេអូដែលគោរពតាមទ្រង់ទ្រាយដូចបានបញ្ជាក់ ទើបត្រូវបានទទួលយកមកពិចារណា។

## VII. ទ្រង់ទ្រាយនៃវីដេអូ

- វីដេអូត្រូវមានរយៈពេលមិនយូរជាង៩នាទី
- គុណភាពនៃវីដេអូទាបបំផុតត្រឹម HD (1280x720)
- វីដេអូត្រូវមានទំហំមិនលើសពី ២ Gb
- មានតែវីដេអូដែលមានការផ្តល់ក្រេឌីត (Credit scene) ត្រឹមត្រូវនៅចុងបញ្ចប់ ដូចដែលបានបង្ហាញក្នុងរូបភាពខាងក្រោមនឹងត្រូវបានទទួលយកមកពិចារណា។

ដែលរៀបចំដោយ :
organised by :

និងគាំទ្រដោយ :
and supported by :

## VIII. លក្ខន្តិកក្នុងការវិនិច្ឆ័យជ្រើសរើស

- ភាពដើមនៃវីដេអូ ១០%
- ភាពរលូននៃដំណើរនៃសាច់រឿង ១០%
- គុណភាពនៃវីដេអូ រួមមានភាពច្បាស់ ភាពទាក់ទាញ និងភាពប៉ិនប្រសព្វនៃការផលិត ១៥%
- ភាពច្នៃប្រឌិតនៃវីដេអូ ១៥%
- អត្ថន័យនៃវីដេអូ ៣៥%
- ការធ្វើបទបង្ហាញនៃដំណើរការនៃការផលិតវីដេអូរួមមាន ការសហការរួមចំណែកក្នុងក្រុម បញ្ហាប្រឈម ចំណុចដែលបានរៀនសូត្រ គោលគំនិតអប់រំ និងអត្ថន័យរួមរបស់វីដេអូ ១៥%